សាលាឧទ្ធរណ៍

**សំណុំរឿងព្រហ្មទណ្ឌ**

លេខ: ១១៧១

ចុះថ្ងៃទី១២-១២-២០១២

**សាលដីកា**

លេខ: ១៣ "ក្រ II សវ"

ចុះថ្ងៃទី២៤-០២-២០១៤

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## តាមនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តីដែលប្រកាសឲ្យប្រើតាមក្រឹត្យលេខ០៦ ក្រ ចុះថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលសវនាការសាលាឧទ្ធរណ៍ នាថ្ងៃទី ០៤ ខែកុម្ភៈ ឆ្នាំ២០១៤ ដោយមានសមាសភាពដូចខាងក្រោម:

**សមាសភាពក្រុមប្រឹក្សា**

-ឯកឧត្តម [redacted] ប្រធាន

-លោក [redacted] ចៅក្រមប្រឹក្សា

-លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញា

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ១១៧១ ចុះថ្ងៃទី ១២ ខែធ្នូ ឆ្នាំ២០១២ ដែលមាន:

-ជនជាប់ចោទឈ្មោះ SHUM[redacted]ភេទប្រុស អាយុ ៦៤ឆ្នាំ ជនជាតិចិនហុងកុង មុខរបរនាយកក្រុមហ៊ុន កើតនៅ[redacted] ទីលំនៅសព្វថ្ងៃផ្ទះលេខ [redacted] ឪពុកឈ្មោះ[redacted] (ស) ម្តាយឈ្មោះ[redacted] (ស) ប្រពន្ធឈ្មោះ[redacted](រ) មានកូន ២នាក់ ទោសពីមុនគ្មាន ។

-ជាប់ចោទពីបទ: ចេញមូលប្បទានប័ត្រគ្មានទឹកប្រាក់ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីឆ្នាំ២០០៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា ២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ឆ្នាំ២០០៥។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] ភេទប្រុស អាយុ ៣១ឆ្នាំ ជាតិខ្មែរ មុខរបរក្រុមហ៊ុនចែកចាយប្រេង ទីលំនៅសព្វថ្ងៃផ្ទះលេខ [redacted]

ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ:

តាមពាក្យបណ្តឹង ចុះថ្ងៃទី ២១ ខែមីនា ឆ្នាំ២០១២ របស់ឈ្មោះ [redacted] សំបូរ ប្តឹងពីឈ្មោះ SHUM [redacted] ពីបទ ចេញមូលប្បទានប័ត្រគ្មានទឹកប្រាក់ ព្រោះនៅឆ្នាំ២០០៩ ខ្លួនបានចុះកិច្ចព្រមព្រៀងផ្គត់ផ្គង់ប្រេង ជាមួយឈ្មោះ SHUM [redacted] ជានាយកក្រុមហ៊ុន UNION PAPER CORPRATION ។ បន្ទាប់ពីចុះកិច្ចសន្យាសហការណ៍ផ្គត់ផ្គង់ប្រេងរួច ខ្លួនបានដឹកប្រេងផ្គត់ផ្គង់ឲ្យក្រុមហ៊ុនដែលបាន ចុះកិច្ចសន្យាគ្រប់ចំនួនលុះដល់ថ្ងៃកំណត់ទូទាត់ប្រាក់បែរជាឈ្មោះ SHUM [redacted] ដោយបានចេញមូលប្បទានប័ត្រលសន្លឹក លេខ ៤៦៩៦៦៩ ទឹកប្រាក់ចំនួន ៤០០០ដុល្លា,មូលប្បទានប័ត្រលេខ ៤៦៩៦៦៧ ទឹកប្រាក់ចំនួន ៤០០០ដុល្លា, មូលប្បទានប័ត្រលេខ ៤៦៩៦៦៨ ទឹកប្រាក់ចំនួន ៤០០០ដុល្លា, មូលប្បទានប័ត្រលេខ ៤៦៩៦៧០ ទឹកប្រាក់ចំនួន ៣០៨០ដុល្លា, មូលប្បទានប័ត្រ លេខ ៤៩២០២០ ទឹកប្រាក់ចំនួន ៤៥៦០ដុល្លា, មូលប្បទានប័ត្រលេខ ៤៩២០៤៩ ទឹកប្រាក់ចំនួន ៤០០០ដុល្លា និងមូលប្បទានប័ត្រលេខ ៥៦៥៧៤៥ទឹកប្រាក់ចំនួន១១៨២ដុល្លាដែលជាទឹកប្រាក់សម្រាប់សងថ្លៃប្រេងសរុបចំនួន ២៤៨២២ដុល្លា ហើយមូលប្បទានប័ត្រខាងលើត្រូវបានភ្នាក់ងារធនាគារបញ្ជាក់ថា មូលប្បទានប័ត្រខាងលើមិនគ្រប់គ្រាន់ ដោយបច្ចុប្បន្ននេះត្រូវបានឃុំខ្លួននៅពន្ធនាគាររួចហើយ។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៥១ ឋ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:

-ផ្តន្ទាទោស:

ក-ឈ្មោះ SHUM [redacted] ភេទប្រុស អាយុ ៦៤ឆ្នាំ ជនជាតិចិនហុងកុង ដាក់ពន្ធនាគារកំណត់រយៈពេល ២ (ពីរឆ្នាំ)។ ពីបទ ចេញមូលប្បទានប័ត្រគ្មានទឹកប្រាក់ ប្រព្រឹត្តនៅរាជធានីភ្នំពេញកាលពីឆ្នាំ២០០៩ បទល្មើសព្រហ្មទណ្ឌដែលបានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា ២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ឆ្នាំ២០០៥។

ខ-បង្គាប់ឲ្យជនជាប់ចោទឈ្មោះSHUM [redacted] ភេទប្រុសអាយុ ៦៤ឆ្នាំជនជាតិចិនហុងកុង សងប្រាក់ថ្លៃប្រេងចំនួន ២៤៨២២ដុល្លា (ពីរម៉ឺនបួនពាន់ប្រាំបីរយម្ភៃពីរដុល្លាអាមេរិក) ទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]។

សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈនៅថ្ងៃទី ០៥ ខែតុលា ឆ្នាំ២០១២ ចំពោះមុខជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី។ បើកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

-បានឃើញបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១៩ ខែតុលា ឆ្នាំ២០១២ របស់ឈ្មោះ SHUM [redacted] ជាជនជាប់ចោទ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៥១ ឋ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ គ្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

-បានឃើញ សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍។

-បានឃើញ របាយការណ៍រឿងព្រហ្មទណ្ឌរបស់ចៅក្រមរបាយការណ៍សភាព្រហ្មទណ្ឌ នៃសាលាឧទ្ធរណ៍។

**នាពេលសវនាការ**

-ជនជាប់ចោទឈ្មោះ SHUM [redacted] (អវត្តមាន)

-ដើមបណ្តឹងឈ្មោះ [redacted] (អវត្តមាន)

តំណាងមហាអយ្យការបានធ្វើការ សន្និដ្ឋានថាៈ មានពិរុទ្ធគ្រប់គ្រាន់លើជនជាប់ចោទពីបទចេញមូលប្បទានប័ត្រគ្មានទឹកប្រាក់ ហេតុនេះ សូមក្រុមប្រឹក្សាសម្រេចតម្កល់សាលក្រមលេខ ៩១ ឋ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញទុកជាបានការ។

**សភាព្រហ្មទណ្ឌ យល់ឃើញថាៈ**

១-បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១៩ ខែតុលា ឆ្នាំ២០១២ របស់ឈ្មោះ SHUM [redacted] ប្តឹងឧទ្ធរណ៍នឹងសាលក្រម ព្រហ្មទណ្ឌលេខ ៩១ ឋ ចុះថ្ងៃទី ០៩ ខែតុលា ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេចបានធ្វើឡើងត្រឹមត្រូវក្នុងកំណត់ច្បាប់សភាព្រហ្មទណ្ឌទទួលជំនុំជម្រះបានយោងតាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-តាមលទ្ធផលនៃកិច្ចពិភាក្សាដេញឃើញថា ជនជាប់ចោទឈ្មោះ SHUM [redacted] បានឆ្លើយសារភាពថាកាលពីឆ្នាំ២០០៩ ខ្លួនពិតជាបានចេញមូលប្បទានប័ត្រគ្មានសាច់ប្រាក់ចំនួនប្រាំពីរសន្លឹកដែលសរុបទឹកប្រាក់ ចំនួន ២៤៨២២ ដុល្លារអាមេរិក ដោយមូលហេតុថាការរកស៊ីរបស់ខ្លួនត្រូវបរាជ័យ។ ផ្អែកតាមចម្លើយរបស់ជនជាប់ ចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី ព្រមទាំងភស្តុតាងនានា ឃើញថាជនជាប់ចោទពិតជាបានប្រព្រឹត្តអំពើ មានពិរុទ្ធភាពគ្រប់គ្រាន់ដាក់បន្ទុកលើជនជាប់ចោទពីបទ ចេញមូលប្បទានប័ត្រគ្មានទឹកប្រាក់បំពានមាត្រា ២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាននិងប្រតិបត្តិការទូទាត់សងប្រាក់ដែលគប្បីផ្តន្ទាទោសជននេះតាមច្បាប់។

៣-សាលក្រមព្រហ្មទណ្ឌលេខ ៩១ ឋ ចុះថ្ងៃទី ០៩ ខែតុលា ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញដែលសម្រេចមកនេះមានលើកសំអាងហេតុសព្វគ្រប់ និងមានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយគួរសភាព្រហ្មទណ្ឌតម្កល់ទុកជាបានការដដែល។

**ហេតុដូច្នេះ មិនិច្ឆ័យសេចក្តីៈ**

១-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១២ របស់ឈ្មោះ SHUM [redacted] ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយខុសគតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៩១ ឋ ចុះថ្ងៃទី ០៩ ខែតុលា ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញទុកជាបានការ។

៣-សាលដីកានេះជំនុំជម្រះកាលពីថ្ងៃទី ០៤ ខែកុម្ភៈ ឆ្នាំ២០១៤ និងប្រកាសជាសាធារណៈ ថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ២០១៤ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីនិងជនជាប់ចោទ។

បើកសិទ្ធិប្តឹងតវ៉ាក្នុងកំណត់ច្បាប់។

<u>សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកាស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និងកងកំលាំងប្រដាប់អាវុធជួយ សហការណ៍អនុវត្តសាលដីកានេះអោយបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់។</u>

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
| --- | --- | --- |
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted], [redacted] | ហត្ថលេខា: [redacted] |

---

បានឃើញ
ប្រធានសាលាឧទ្ធរណ៍

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ ថ្ងៃទី០៩...ខែ១២...ឆ្នាំ២០១៤
ក្រឡាបញ្ជី

[redacted]